# អារម្ភកថា

ដំណើរការខូចខាតដីដូចជា ភាពរាំងស្ងួត សំណឹកដី រឺការបំពុលដីកំពុងតែកើតឡើងជាញឹកញាប់ ហើយជាលទ្ធផលធ្វើអោយផលិតភាពដីធ្លាក់ចុះជាលំដាប់ ។ ការហូរនាំនៃសារធាតុគីមីកសិកម្មដែលបានប្រើប្រាស់លើផ្ទៃដីទៅក្នុងផ្លូវទឹកធ្វើអោយមានការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់គុណភាពទឹក ។

ហេតុដូច្នេះហើយទើបធ្វើអោយមានការចាប់អារម្មណ៍លើការអនុវត្តន៍កសិកម្មសមស្រប ។ ការអនុវត្តន៍កសិកម្មសមស្របសំដៅដល់ការផលិតអាហារ និងសារធាតុសសៃនានាក្នុងលក្ខណៈមួយដែលមិនប៉ះពាល់ដល់បរិស្ថានធម្មជាតិ ។

បន្ទាប់ពីការបោះពុម្ពរបស់យើងខ្ញុំលើកមុន " *Sustainable Agriculture with Organic Fertilizer"* សៀវភៅនេះត្រូវបានបោះពុម្ពឡើងក្នុងក្តីសង្ឃឹមផ្សព្វផ្សាយអោយបានទូលំទូលាយអំពីការអនុវត្តន៍កសិកម្មសមស្រប ។ សៀវភៅនេះផ្តោតជាសំខាន់ទៅលើ ដីកំប៉ុស្តិ៍ ជីលាមកសត្វ ដីកំប៉ុស្តិ៍គ្រាប់ ជីទឹកថ្នាំពុលធម្មជាតិ ទឹកខ្មេះឈើនិងធ្យូង ការធ្វើដីបែបអភិរក្ស ការទប់ស្កាត់ការហូរច្រោះ កសិ-រុក្ខកម្ម និងការសាងសង់ស្រះទឹក ដែលជាវិធីសាស្រ្តអាចយកទៅអនុវត្តន៍បានដោយងាយស្រួល ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅមគ្គុទេសនេះក៏នឹងត្រូវបានប្រើជាប្រយោជន៍ ក្នុងការលើកកំពស់ការអនុវត្តន៍កសិកម្មសមស្របតាមរយៈការផ្សព្វផ្សាយដោយភ្នាក់ងារផ្សព្វផ្សាយពីសាកលវិទ្យាល័យ រឺអង្គការក្រៅរដ្ឋាភិបាលនានា ក៏ដូចជាការធ្វើអោយប្រសើរឡើងនូវចំណាប់អារម្មណ៍របស់កសិករនៅមូលដ្ឋាន រឺសិស្សានុសិស្សអោយកាន់តែស៊ីជំរៅថែមទៀតអំពីសារៈប្រយោជន៍នៃកសិកម្មសមស្រប ។

ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៩

ម៉ាឈិតុ មីហារ៉ា និង អាគីមិ ហ្វូជិមូតូ

ប្រធានបណ្ណាធិការ

**ប្រធានបណ្ណាធិការ**

ម៉ាឈិតុ មីហារ៉ា និង អាគីមិ ហ្វូជិមូតូ

*សាកលវិទ្យាល័យកសិកម្មតូក្យូ ប្រទេសជប៉ុន*

**គណៈកម្មការបណ្ណាធិការ**

*សាកលវិទ្យាល័យកសិកម្មតូក្យូ (TUA)*

កេអិស៊ុរ អិតាហ្គាគិ ហ៊ីរូគិ អិណាយហ្សូមិ អាគិល មូហាម៉ាដ និង កូលីន អាន់គើសិន

*វិទ្យាស្ថានកែលំអ និងអភិរក្សបរិស្ថាន (អេរ៉ីកុន)*

តាកាស៊ិ អុអិនុ និង ជិកា អ៊ីស៊ិយ៉ាម៉ាក់

*សាកលវិទ្យាល័យកាសេដសាត (ខេយូ) ប្រទេសថៃ*

ថាវ៉ាន់សាក់ ផូវសាង

*សាកលវិទ្យាល័យខុនឃេន (ខេខេយូ) ប្រទេសថៃ*

វិដហាយ៉ា ទ្រេឡូ-ហ្គេស និង ម៉ុងឃុន តា-អ៊ូន

*សមាគមន៍អភិវឌ្ឍន៍បរិស្ថាន និងជនបទ (អ៊ើដ) ប្រទេសថៃ*

ឡាលីតា សិរីវឌ្ឍនានុន និង ចេរ៉ានុច សាក់ខាំខួង

*សាកលវិទ្យាល័យភូមិន្ទកសិកម្ម (សវភក) ប្រទេសកម្ពុជា*

ង៉ោ ប៊ុនថាន និង សេង ចិន្តា

**អ្នកនិពន្ធ**

អាគីមិ ហ្វូជិមូតុ (ធីយូអេ, ជប៉ុន): ជំពូក ១

យូហេអិ ហាស៊ិមូតុ (សាកល. ជីហ្វុ, ជប៉ុន): ជំពូក ២

ហ៊ីរូគិ អិណាយហ្សូមិ (ធីយូអេ, ជប៉ុន): ជំពូក ៣

កេអិស៊ុរ អិតាហ្គាគិ (ធីយូអេ, ជប៉ុន): ជំពូក ១

សេអិ កាវ៉ាក់មូរ៉ាក់ (ធីយូអេ, ជប៉ុន): ជំពូក ២

ម៉ាឈិតុ មីហារ៉ា (ធីយូអេ, ជប៉ុន): ជំពូក ១, ២, ៣

អាគិល មូហាម៉ាដ (ធីយូអេ, ជប៉ុន): ជំពូក ១, ២, ៣

ង៉ោ ប៊ុនថាន (សវភក, កម្ពុជា): ជំពូក ២

ហ៊ីរូមុ អូកាហ្សាវ៉ាក់ (ធីយូអេ, ជប៉ុន): ជំពូក ២

ថាវ៉ាន់សាក់ ផូវសាង (ខេយូ, ថៃ): ជំពូក ២

យូ សាអិតុ (ធីយូអេ, ជប៉ុន): ជំពូក ២

ចេរ៉ានុច សាក់ខាំឌួង (អ៊ើដ, ថៃ): ជំពូក ១, ២, ៣

ឡាលីតា សិរីវឌ្ឍនានុន (អ៊ើដ, ថៃ): ជំពូក ១, ២, ៣

គីយ៉ូស៊ិ តាជីម៉ាក់ (ធីយូអេ, ជប៉ុន): ជំពូក ២

កូតារុ តាកាវ៉ាដាក់ (ធីយូអេ, ជប៉ុន): ជំពូក ២

ម៉ុងឃុន តា-អ៊ូន (សាកល. ឃុនខេន, ថៃ): ជំពូក ២

ជូលៀន តូរីឡូ ចេអ. (ធីយូអេ, ជប៉ុន): ជំពូក ២

វិដហាយ៉ា ទ្រេឡូ-ហ្គេស (សាកល. ឃុនខេន, ថៃ): ជំពូក ២

កេនជី យូកូតាក់ (ធីយូអេ, ជប៉ុន): ជំពូក ២

(រៀបតាមលំដាប់តួអក្សរឡាតាំង)



## មាតិកា

**អារម្ភកថា**

**មាតិកា**

**I. សេចក្តីផ្តើម**

១.១ បញ្ហាបរិស្ថាននៃការអនុវត្តន៍កសិកម្មក្នុងពេលថ្មីៗនេះ

១.២ គោលការណ៍នៃការអនុវត្តន៍កសិកម្មសមស្រប

**II. ការអនុវត្តន៏កសិកម្មសមស្រប**

២.១ ជីកំប៉ុស្តិ៍

២.២ ជីលាមកសត្វ

២.៣ ជីកំប៉ុស្តិ៍គ្រាប់

២.៤ ជីទឹក

២.៥ ថ្នាំពុលធម្មជាតិ

២.៦ ទឹកខ្មេះឈើ និងធ្យូង

២.៧ ការធ្វើជីបែបអភិរក្ស

២.៨ ការទប់ស្កាត់ការហូរច្រោះ

២.៩ កសិ-រុក្ខកម្ម

២.១0 ការសាងសង់ស្រះទឹក

**III. សេចក្តីសន្និដ្ឋាន**

**ឯកសារយោង**

# I. សេចក្តីផ្តើម

## ១.១ បញ្ហាបរិស្ថាននៃការអនុវត្តន៍កសិកម្មក្នុងពេលថ្មីៗនេះ

បម្រែបម្រួលគួរអោយកត់សំគាល់នៃប្រព័ន្ធកសិកម្មបានកើតឡើងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយសាររដ្ឋាភិបាលនៃប្រទេសជាច្រើនបានផ្តល់ថវិកាទំនុកបំរុងលើវិស័យកសិកម្ម ដើម្បីធានាការផ្គត់ផ្គង់អាហារអោយបានគ្រប់គ្រាន់។ ជាលទ្ធផល កសិករភាគច្រើនបានប្រើសារធាតុគីមីកសិកម្មដូចជា ជីគីមី ថ្នាំសំលាប់សត្វល្អិតឬស្មៅ ដើម្បីរក្សាទិន្នផលដំណាំអោយបានខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ការប្រើសារធាតុគីមីកសិកម្មច្រើនហួសហេតុពេកបានប៉ះពាល់ដល់ជីជាតិដី និងផលិតភាពយូរអង្វែងរបស់ដីកសិកម្ម។

សារធាតុគីមីកសិកម្មដែលហូរចេញពីដីកសិកម្មបានធ្វើអោយខូចដល់បរិស្ថានទឹក ។ ការខូចខាតនេះបានកើនឡើងជាបន្តបន្ទាប់ដោយការហូរនាំនៃភាគល្អិតរបស់ដីដែលបណ្តាលមកពីសំណឹកដី (រូបភាព ១.១)។ សំណឹកដីក៏ជាហេតុដែលបណ្តាលអោយបាត់បង់គុណភាពដីផងដែរ តាមរយៈការហូរច្រោះនៃដីមមោកនៅស្រទាប់ដីខាងលើ។ ជីជាតិដែលហូរនាំមកជាមួយសំណឹកដីទាំងនេះ បានធ្លាក់ចូលទៅក្នុងផ្លូវទឹក និងបំពុលដល់ប្រភពទឹក។





**រូបភាព ១.១ លក្ខណៈសំណឹកដី**

ថ្នាំសំលាប់សត្វល្អិតជាទូទៅត្រូវបានផ្សំឡើងពីសារធាតុពុលនានា ហើយនិងសារធាតុចិញ្ចឹមមួយចំនួន ដូចជាអាសូត រឺផូស្វ័រ ដែលជាមូលហេតុនាំអោយកើតមានការបំពុលទឹក (រូបភាព ១.២) ។ ការបំពុលទឹក គឺជាដំណើរការដែលប្រភពទឹកទទួលនូវសារធាតុចិញ្ចឹមច្រើនលើសកំរិត បង្កលក្ខណៈអំណោយផលដល់ការលូតលាស់យ៉ាងឆាប់រហ័សនៃពពួកបួង់តុង និងភាវរស់ក្នុងទឹកផ្សេងៗទៀត ។ ការលូតលាស់យ៉ាងឆាប់រហ័សនេះធ្វើអោយកាត់បន្ថយកំរិតអុកស៊ីសែនរលាយក្នុងទឹក ហើយជាមូលហេតុបណ្តាលអោយភាវរស់ផ្សេងៗស្លាប់បាន ។



**រូបភាព ១.២ ការបំពុលទឹកស្រះ**

ការដុតសំអាតកាកសំណល់រុក្ខជាតិដែលអនុវត្តដោយកសិករត្រូវបានចាត់ទុកថាជាការចាំបាច់ ព្រោះវាជាវិធីងាយស្រួល និងចំណាយតិចក្នុងការសំអាតសំណល់ផ្សេងៗលើដីរបស់គាត់ដើម្បីត្រៀមសំរាប់ការដាំដំណាំបន្ទាប់ ។ ទោះជាយ៉ាងណាក៏ដោយ កំដៅក្នុងពេលដុតនោះបានសំលាប់មីក្រូសរីរាង្គ រឺសត្វល្អិតមានប្រយោជន៏ផ្សេងៗនៅក្នុងដី ។ ចំណែកសមាសភាពនៃសារធាតុចិញ្ចឹមក្នុងសំណល់រុក្ខជាតិដែលមាននៅលើដីនោះក៏ត្រូវបានបាត់បង់តាមរយៈការដុតនេះផងដែរ ។



**រូបភាព ១.៣ ការដុតសំអាតដី**

ការបាញ់ថ្នាំសំលាប់ស្មៅ និងថ្នាំសំលាប់សត្វល្អិត (រូបភាព ១.៤) ដែលមិនមានការយល់ដឹងពីសុវត្ថិភាព នៃការប្រើប្រាស់អាចបង្ករអោយមានបញ្ហាធ្ងន់ធ្ងរជាច្រើនដូចជា ជាតិពុលជាប់ក្នុងផលិតផលកសិកម្ម រឺមាន ជំងឺដល់មនុស្សជាពិសេសគឺជំងឺមហារីកស្បែក (រូបភាព ១.៥)។ ដូច្នេះ ការណែនាំដល់កសិករមូលដ្ឋានអោយ ចេះប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតប្រកបដោយសុវត្ថិភាពត្រូវតែជាអតិភាពខ្ពស់។



**រូបភាព ១.៤ ការបាញ់ថ្នាំសំលាប់សត្វល្អិតដោយគ្មានសុវត្ថិភាព**



**រូបភាព ១.៥ ជំងឺមហារីកស្បែក**




**រូបភាព ១.៦ ការណែនាំអំពីការប្រើប្រាស់ថ្នាំគីមីសំលាប់សត្វល្អិតដោយសុវត្ថិភាព**

## ***១.២ គោលការណ៍នៃការអនុវត្តន៍កសិកម្មសមស្រប***

កសិកម្មសមស្របចូលរួមនូវកត្តាសំខាន់បីនៃបរិស្ថានធម្មជាតិ ចំណូលសេដ្ឋកិច្ច និងសមភាពសង្គម (រូបភាព ១.៧) ។ ទោះជាប្រព័ន្ធកសិកម្មដែលពឹងផ្អែកសារធាតុគីមីកសិកម្មអាចបង្កើនផលិតផលអាហារ និង សារធាតុសរសៃក្នុងរយៈពេលខ្លីក៏ដោយ វាក៏បណ្តាលអោយមានបញ្ហាញបរិស្ថានជាច្រើន ។ ប្រព័ន្ធនេះក៏អនុញ្ញាត អោយកសិករចំនួនតិចផលិតអាហារ និងសារធាតុសរសៃបានច្រើនផងដែរ ។




**រូបភាព ១.៧ កត្តាសំខាន់បីយ៉ាងនៃកសិកម្មសមស្រប**

នៅពេលដែលមានការយល់ដឹងពីបរិស្ថានកើនឡើង កសិករជាច្រើននៅតំបន់ផ្សេងៗគ្នាបានចាប់ផ្តើម ផ្លាស់ប្តូរទៅរកការអនុវត្តន៍កសិកម្មសមស្រប ។ ទោះបីជាមានការលំបាកក្នុងការកំណត់និយមន័យអំពី " ភាព សមស្រប " ក្នុងវិស័យកសិកម្មក៏ដោយ ក៏មានការអនុវត្តន៍ជាច្រើនដែលនាំទៅរកកសិកម្មសមស្របដូចជា ការធ្វើកសិកម្មសរីរាង្គ ការដាំដំណាំឆ្លាស់ កសិកម្មចំរុះ កសិ-រុក្ខកម្ម រឺ កសិកម្មសំរាប់ហូបក្នុងគ្រួសារ ។

គុណប្រយោជន៏នៃការអនុវត្តន៏កសិកម្មសមស្របអាចសង្ខេបបានដូចខាងក្រោមៈ

១. ការអនុវត្តន៏កសិកម្មសមស្របត្រូវបានផ្តោតទៅលើការប្រើប្រាស់ធនធានកកើតឡើងវិញ និង/ឬធនធានអាចប្រើប្រាស់ឡើងវិញ។ ការប្រើប្រាស់នៃធនធានអាចកកើតឡើងវិញនៅក្នុងប្រព័ន្ធកសិកម្មអាចមានផលប្រយោជន៏ចំពោះបរិស្ថាន។ ឧទាហរណ៏ សំណល់សត្វ និងរុក្ខជាតិអាចត្រូវបានប្រើដើម្បីធ្វើដីកំប៉ុស្តិ៍ដែលអាចជំនួសសារធាតុគីមី។

២. ការអនុវត្តន៏កសិកម្មសមស្របជួយការពារប្រព័ន្ធបរិស្ថានទាំងមូល ដែលនាំអោយធនធានធម្មជាតិអាចកកើតឡើងវិញជាបន្តបន្ទាប់។ ប្រព័ន្ធដំណាំវិលជុំដែលបានអនុវត្តដោយកសិករមួយចំនួនតូចនៅតំបន់ភ្នំអនុញ្ញាតអោយព្រៃឈើដុះលូតលាស់ឡើងវិញតាមរយៈការកាប់រុក្ខជាតិតូចៗ និងរក្សាទុកដើមឈើធំៗ។

៣. ការអនុវត្តន៏កសិកម្មសមស្របជួយបង្កើនគុណភាពនៃជីវិតរបស់បុគ្គលម្នាក់ និងសហគមន៏ទាំងមូល។ ដើម្បីអនុវត្តកសិកម្មសមស្រប កសិករធ្វើសកម្មភាពមួយចំនួនដែលជួយបង្កើតប្រាក់ចំណូលជាមួយនឹងការចំណាយតិច។

៤. ប្រព័ន្ធកសិកម្មសមស្របគឺជាប្រព័ន្ធផ្តល់គុណប្រយោជន៏ ។ ការបញ្ជូនចំណេះដឹងអំពីការអនុវត្តន៏កសិកម្មសមស្របពីជំនាន់មួយទៅជំនាន់មួយទៀត មានផលប្រយោជន៏ខ្លាំងណាស់សំរាប់មនុស្សជំនាន់ក្រោយ។ ការពិភាក្សាអំពីការអនុវត្តន៏កសិកម្មសមស្របរវាងសហគមន៏ផ្សេងគ្នា ក៏ជួយពង្រឹងចំណេះដឹងរបស់ប្រជាជនមូលដ្ឋានអោយកាន់តែទូលំទូលាយផងដែរ។

## II. ការអនុវត្តន៍កសិកម្មសមស្រប

ការអនុវត្តន៍កសិកម្មសមស្របត្រូវបានចាប់អារម្មណ៍ និងប្រតិបត្តិដើម្បីសម្រេចបានកសិកម្មនិងបរិស្ថានប្រកបដោយនិរន្តរភាព។ បច្ចុប្បន្ន មានការអនុវត្តន៍កសិកម្មសមស្របជាច្រើនដែលត្រូវបានគេកំពុងសិក្សា និងលើកគំរោងសិក្សា។ ការអនុវត្តន៍កសិកម្មសមស្របដូចជា ជីកំប៉ុស្តិ៍ លាមកសត្វ ជីកំប៉ុស្តិ៍គ្រាប់ ជីទឹកថ្នាំពុលធម្មជាតិ ទឹកខ្មេះឈើនិងធ្យូង ការធ្វើជីបែបអភិរក្ស ការទប់ស្កាត់ការហូរច្រោះ កសិ-រុក្ខកម្ម និងការសាងសង់ស្រះទឹក ជាវិធីងាយៗដែលកសិករមូលដ្ឋានអាចអនុវត្តបានសំរាប់ដីកសិកម្មរបស់គាត់។ ប៉ុន្តែការអនុវត្តន៍ទាំងនេះអាចត្រូវផ្លាស់ប្តូរ ឬកែរតំរូវអោយត្រូវទៅតាមវត្ថុធាតុដើម និងសេចក្តីត្រូវការក្នុងតំបន់។



**រូបភាព ២. ១ ការអនុវត្តន៍កសិកម្មសមស្របនៅតំបន់ជំរាលភ្នំ ខេត្ត ឈៀង រ៉ៃ ប្រទេសថៃ**

## ២.១ ជីកំប៉ុស្តិ៍

ជីកំប៉ុស្តិ៍ដែលជាប្រភេទជីសរីរាង្គផ្សំចេញពីសំណល់រុក្ខជាតិ គឺជាសារធាតុដ៏មានប្រសិទ្ធភាពក្នុងការបង្កើនលក្ខណៈរូប និងលក្ខណៈគីមីរបស់ដី។ ដំណើរការបំបែកធាតុជាកំប៉ុស្តិ៍ដោយពពួកមីក្រូសរីរាង្គត្រូវការពេលវេលាពី ១ ទៅ ៣ខែ។ ក្នុងកំឡុងពេលឡើងមេ សីតុណ្ហភាពនៃសារធាតុធ្វើកំប៉ុស្តិ៍នេះអាចកើនដល់ ៥០ ទៅ ៧០ អង្សាសេ។ ជីកំប៉ុស្តិ៍ផ្តល់សារៈប្រយោជន៏ក្នុងការបង្កើនសារធាតុសរីរាង្គក្នុងដី បង្កើនទំរង់ដី និងជួយរក្សាសំណើមរបស់ដី។

### ២.១.១ វត្ថុធាតុដើមសំរាប់ធ្វើជីកំប៉ុស្តិ៍

- សំណល់រុក្ខជាតិដូចជា ចំបើង ស្លឹកអំពៅ សំណល់សណ្តែក អាចម៍រណា សំណល់ពោត ស្មៅ ស្លឹករុក្ខជាតិ ។ល។
- ដីដែលមានជីជាតិ (ខ្មៅ ហ្មត់ និងមានសំណើម)
- លាមកសត្វ
- ពពួកមីក្រូសរីរាង្គមួយចំនួនដែលមានប្រសិទ្ធភាពសំរាប់ការបំបែកជាកំប៉ុស្តិ៍



**រូបភាព ២.២ សំណល់រុក្ខជាតិប្រើជាវត្ថុធាតុដើមសំរាប់ធ្វើជីកំប៉ុស្តិ៍**

## ២.១.២ របៀបធ្វើជីកំប៉ុស្តិ៍

មានរបៀបជាច្រើនសំរាប់ធ្វើជីកំប៉ុស្តិ៍។ រូបភាព ២.៣ បង្ហាញអំពីរបៀបធ្វើជីកំប៉ុស្តិ៍ពេញនិយមក្នុងចំណោមកសិករមូលដ្ឋាន។




១) រៀបចំជាពំនូក ហើយគ្របជាមួយនឹងផ្លាស្ទិក រួចស៊កបំពង់មានរន្ធចូលក្នុងពំនូកដី




២) ដាក់លើដីដោយមិនគ្រប រួចស៊កបំពង់មានរន្ធ




៣) ដាក់ក្នុងរណ្តៅដីហើយគ្របដីពីលើ




៤) ដាក់ក្នុងប្រអប់ដោយមានបំពង់ចោះរន្ធ

**រូបភាព ២.៣ របៀបធ្វើជីកំប៉ុស្តិ៍ផ្សេងៗគ្នា**

## ២.១.៣ ជំហ៊ានក្នុងការធ្វើជីកំប៉ុស្តិ៍

១) តំរៀបសំណល់រុក្ខជាតិ ដី និង/រឺ លាកមកសត្វ ទៅក្នុងប្រអប់ធ្វើជីកំប៉ុស្តិ៍



២) ស្រោចទឹកអោយជោគ និងហាប់ បន្ទាប់មកគ្របវាដើម្បីកុំអោយភ្លៀងហូរច្រោះ



៣) ប្រសិនបើអត់មានបំពង់ខ្យល់ចេញចូលទេ ត្រូវកាយត្រឡប់វៀងរាល់សប្តាហ៍



## ***២.១.៤ បច្ចេកទេសធ្វើជីកំប៉ុស្តិ៍***

ប្រភេទ ១: ដាក់ជាស្រទាប់ៗទៅតាមប្រភេទវត្ថុធាតុដើម ហើយស្រោចទឹកគ្រប់ស្រទាប់នីមួយៗ



ប្រភេទ ២: ចូកត្រឡប់សារធាតុទាំងអស់អោយសព្វចូលគ្នា រួចហើយស្រោចទឹកអោយជោគ



***កំណត់សំគាល់:***

- ជីជាតិនៅក្នុងជីកំប៉ុស្ដិ៍ និងរយៈពេលនៃការឡើងមេខុសគ្នាអាស្រ័យទៅតាមប្រភេទវត្ថុធាតុដើម
- មីក្រូសរីរាង្គមានប្រសិទ្ធភាពដែលដាក់បន្ថែមទៅលើវត្ថុធាតុដើមជួយពន្លឿនដំណើរការនៃការឡើងមេ
- វត្ថុធាតុដើមដែលមានកំរិតអាសូតច្រើនក៏ជួយពន្លឿនការឡើងមេផងដែរ
- កត្តាសំខាន់បីយ៉ាងដែលជួយបង្កើនការបំបែកធាតុជាជីកំប៉ុស្ដិ៍គឺ សំណើម ខ្យល់ និងពពួកមីក្រូសរីរាង្គ



**រូបភាព ២.៤ ការធ្វើជីកំប៉ុស្ដិ៍ក្នុងថ្រុង នៅខេត្តកំពង់ចាម ប្រទេសកម្ពុជា**

## ២.២ ជីលាមកសត្វ

កាកសំណល់នៃការចិញ្ចឹមសត្វដូចជា លាមកគោ ក្របី ឬមាន់ មានជីជាតិ និងសារធាតុសរីរាង្គច្រើន។ តាមរយៈដំណើរការឡើងមេ លាមកទាំងនេះបម្លែងទៅជាជីសរីរាង្គដ៏ល្អហៅថាជីលាមកសត្វ។ ប៉ុន្តែ ការទុកដាក់កាកសំណល់នៃការចិញ្ចឹមសត្វមិនបានសមស្របអាចនាំទៅរកបញ្ហាបរិស្ថានធ្ងន់ធ្ងរដូចជា ការហូរចេញនៃអាសូត ផូស្វ័រ មេរោគ រីសត្វល្អិតចង្រៃ បន្ថែមពីលើការបំពុលដោយក្លិន។

### ២.២.១ សម្ភារៈសំរាប់ការធ្វើជីលាមកសត្វ

- ប្រភេទលាមកសត្វចិញ្ចឹមណាមួយដូចជា អាចម៍គោ រឺ មាន់




**រូបភាព ២.៥ គំនរលាមកសត្វ**

### ២.២.២ របៀបធ្វើជីលាមកសត្វ

លាកមកសត្វត្រូវលាយបញ្ចូលគ្នា គរជាពំនូកខ្ពស់ជាង ១ម៉ែត្រ ហើយគ្របជាមួយនឹងក្រណាត់ផ្លាស់ស្ទិកដើម្បីបង្កើនសីតុណ្ហភាពក្នុងកំឡុងពេលឡើងមេ (រូបភាព ២.៥)។ ជាទូទៅត្រូវការរយៈពេល ១ខែ ដើម្បីអោយលាកមកសត្វទាំងនេះឡើងមេ។



**រូបភាព ២.៦ លាមកគោមុន និងក្រោយពេលទុកអោយឡើងមេរយៈពេល ១ខែ**

***កំណត់សំគាល់:***

- ដំណើរការឡើងមេមានសារៈសំខាន់ណាស់សំរាប់ការកំចាត់ពពួកមេរោគ និងមីក្រូសរីរាង្គគ្រោះថ្នាក់នានា ដូចជាអ៊ី-កូឡៃ (E-coli)
- ការដាក់បន្ថែមមីក្រូសរីរាង្គដែលមានប្រសិទ្ធភាព អាចជួយបង្កើនល្បឿនដល់ការឡើងមេ
- មានកត្តាសំខាន់បីយ៉ាងដែលជំរុញដល់ការឡើងមេនៃលាមកសត្វរួមមាន សំណើម ខ្យល់ និងមីក្រូសរីរាង្គ ក៏ដូចជាការបំបែកធាតុនៃសំណល់រុក្ខជាតិផងដែរ ។



**រូបភាព ២.៧ គំនរលាមកគោ**

## ២.៣ ដីកំប៉ុស្តិ៍គ្រាប់

ដោយសារដង់ស៊ីតេនៃដីកំប៉ុស្តិ៍ប្រហែល ១,៩ក្រាម/ស.ម[៣] តូចជាងដង់ស៊ីតេនៃដីដែលមាន ២,៧ក្រាម/ស.ម[៣] ធ្វើអោយទឹកភ្លៀង ឬទឹកហូរលើផ្ទៃដីអាចហូរនាំយកដីកំប៉ុស្តិ៍ដោយងាយជាងដី ។ ដើម្បីបង្កើនភាពជាប់ប្រឆាំងនឹងការហូរច្រោះ និងដើម្បីរក្សាអោយដីកំប៉ុស្តិ៍នៅលើដីបានយូរ នោះដីកំប៉ុស្តិ៍គ្រាប់ពិតជាមានគុណសម្បត្តិ។ ម្យ៉ាងទៀត ដីកំប៉ុស្តិ៍គ្រាប់ផ្តល់ភាពងាយស្រួលច្រើនដល់កសិករក្នុងការដឹកជញ្ជូន និងបាចទៅលើដីកសិកម្មរបស់គាត់បើប្រៀបធៀបទៅនឹងដីកំប៉ុស្តិ៍ធម្មតា ព្រោះវាមានទំរង់ជាគ្រាប់ ។

### ២.៣.១ សម្ភារៈសំរាប់ធ្វើដីកំប៉ុស្តិ៍គ្រាប់

- ដីកំប៉ុស្តិ៍ធម្មតា ធ្វើពីសំណល់រុក្ខជាតិ ឬលាមកសត្វ
- ដីឥដ្ឋ
- ស្ករង្គូ




**រូបភាព ២.៨ សម្ភារៈ និងដំណើរការនៃការផលិតដីកំប៉ុស្តិ៍គ្រាប់**

### ២.៣.២ របៀបផលិតដីកំប៉ុស្តិ៍គ្រាប់

អត្រាល្បាយនៃដីកំប៉ុស្តិ៍ធម្មតា ដីឥដ្ឋ និងស្ករង្គូគួរតែមានភាគរយ ១០ : ១ : ០,០១ ដូចបង្ហាញក្នុង

រូបភាព ២.៨។ ដីឥដ្ឋ និងស្ករង្វ ប្រើសំរាប់ធ្វើអោយកំប៉ុស្តិ៍ស្អិតជាប់គ្នា។ ទឹកក៏ត្រូវបានបន្ថែមទៅលើដំណើរការនៃការផលិតជីកំប៉ុស្តិ៍គ្រាប់នេះដែរ។

មានវិធីពីរយ៉ាងក្នុងការធ្វើជីកំប៉ុស្តិ៍វាយទៅជាជីកំប៉ុស្តិ៍គ្រាប់គឺធ្វើដោយដៃ និងដោយម៉ាស៊ីន (រូបភាព ២.៩, ២.១០)។ ការធ្វើដោយម៉ាស៊ីនអាចផលិតជីកំប៉ុស្តិ៍គ្រាប់បានលឿនជាងការធ្វើដោយដៃ។



**រូបភាព ២.៩ ជីកំប៉ុស្តិ៍គ្រាប់ផលិតដោយដៃ**



**រូបភាព ២.១០ ជីកំប៉ុស្តិ៍គ្រាប់ផលិតដោយម៉ាស៊ីន**

***កំណត់សំគាល់:***

- គួរចាប់អារម្មណ៍ទៅលើបរិមាណនៃស្ករង្វដែលបានថែម។ ការលូតលាស់នៃរុក្ខជាតិអាចមានបញ្ហាប្រសិនបើដាក់ស្ករង្វច្រើនជាងភាគរយដែលបានលើកឡើងខាងលើ។

## ២.៤ ជីទឹក

ជីទឹក គឺជាសារធាតុរាវដែលបានពីសំណល់សត្វ រឺរុក្ខជាតិដែលបានបម្លែងជាកំប៉ុស្តិ៍តាមរយៈការឡើងមេដោយមីក្រូសរីរាង្គនានា។ ក្នុងដំណើរការឡើងមេជាការចាំបាច់ត្រូវបន្ថែមស្ករឬ ឬស្ករធម្មតាដើម្បីចិញ្ចឹមពពួកមីក្រូសរីរាង្គទាំងនោះ។

មានបណ្តុំសារធាតុផ្សេងគ្នាជាច្រើននៅក្នុងកោសិការុក្ខជាតិ និងសត្វដូចជា កាបូនឌីអុកស៊ីត ប្រូតេអ៊ីន អាមីណូអាស៊ីត ជីវជាតិរុក្ខជាតិ អង់ស៊ីម ឬអកមូនរុក្ខជាតិ ដែលអាចប្រើប្រាស់សំរាប់ធ្វើជីទឹកបាន។

### ២.៤.១ វត្ថុធាតុដើមសំរាប់ការធ្វើជីទឹក

មានរូបមន្តជាច្រើនក្នុងការបង្កើតជីរាវដើម្បីអោយស្របទៅតាមគោលបំណងរបស់កសិករ ឬដើម្បីគាត់អាចទទួលយកបាន។ វត្ថុធាតុដើមនៅក្នុងតំបន់ដែលអាចរកបានមានដូចខាងក្រោម:

- សំណល់រុក្ខជាតិ
- សំណល់សត្វ
- ផ្លែឈើទុំ
- សំណល់ពីផ្ទះបាយ រឺសំណល់អាហារផ្សេងៗ
- ស្ករឬ រឺស្ករធម្មតា

### ២.៤.២ របៀបបង្កើតជីទឹក

ជីទឹកត្រូវបានបង្កើតពីសំណល់រុក្ខជាតិ រឺសត្វដែលបានឡើងមេក្រោមលក្ខខ័ណ្ឌមានខ្យល់ រឺគ្មានខ្យល់។ ការបន្ថែមមីក្រូសរីរាង្គមានប្រសិទ្ធភាពមួយចំនួន អាចជួយអោយការបម្លែងកាន់តែលឿន។ ក្រៅពីការបន្ថែមពពួកមីក្រូសរីរាង្គមានប្រសិទ្ធភាពមួយចំនួន ស្ករឬ រឺស្ករធម្មតាក៏មានសារៈសំខាន់សំរាប់ធ្វើជាអាហាររបស់ពពួកមីក្រូសរីរាង្គផងដែរ។

១) ចិញ្ច្រាំវត្ថុធាតុដើមទាំងអស់អោយល្អិតៗ

 

២) លាយវត្ថុធាតុដើមទាំងអស់ដែលបានចិញ្ច្រាំរួចជាមួយនឹងស្ករវង្វ ឬស្ករធម្មតា។ មីក្រូសរីរាង្គមានប្រសិទ្ធភាពនានាអាចបន្ថែមនៅទីនេះ

 

៣) ដាក់វត្ថុធាតុដើមដែលលាយហើយទាំងអស់ទៅក្នុងធុងសំរាប់ឡើងមេ ថែមទឹក និងកូរអោយសប់



ដំណើរការបម្លែងជាជីកំប៉ុស្តិ៍ត្រូវការពេលប្រហែល ៣០-៦០ ថ្ងៃ។ ក្រោយពេលបញ្ចប់ដំណើរការឡើងមេនេះ ទឹកពណ៌ត្នោតមានក្លិនដូចអាកុល (រូបភាព ២.៩) នឹងកើតមាននៅក្នុងធុង។ កាលណាវានៅមានក្លិនស្អុយ រឺក្លិនចំឡែកខុសពីអាកុល មានន័យថាដំណើរការឡើងមេនេះនៅមិនទាន់បញ្ចប់នៅឡើយទេ។ នៅពេលនេះគួរបន្ថែម ស្ករវង្វ រឺស្ករធម្មតាទៀត។




**រូបភាព ២.១១ ជីទឹក**

***កំណត់សំគាល់:***

- ក្នុងកំឡុងពេលដំណើរការឡើងមេមិនត្រូវបិតគំរបធុងជិតពេកទេ
- ដើម្បីបង្កើនក៏រិតអុកស៊ីសែន ត្រូវកូរល្បាយក្នុងធុងរៀងរាល់ ៣ថ្ងៃម្តង
- បន្ទាប់ពីធ្វើជីទឹកនេះរួចហើយ ត្រូវរក្សាធុងទុកក្នុងម្លប់
- ជីទឹកគឺជាជីដែលមានកំហាប់ខ្ពស់។ ត្រូវពង្រាវវាពី ១០ ទៅ ១០០ ដង ជាមួយទឹកមុនពេលប្រើវាទៅលើដំណាំ។

***សេចក្តីបន្ថែម:***

រូបមន្តមួយចំនួនសំរាប់ការផលិតជីរាវមានដូចខាងក្រោម:

*រូបមន្ត ១: ត្រពាំង២គីឡូក្រាម ពន្លកចេក២គីឡូក្រាម ត្រកួន២គីឡូក្រាម ស្លឹកសណ្តែក២គីឡូក្រាម ស្ករអំពៅ ៣គីឡូក្រាម មីក្រូសរីរាង្គ១កញ្ចប់ និង ទឹក៥០លីត្រ*

*រូបមន្ត ២: ចេកទុំ២គីឡូក្រាម ល្ហុងទុំ២គីឡូក្រាម ល្ពៅ២គីឡូក្រាម ស្ករអំពៅ៣គីឡូក្រាម មីក្រូសរីរាង្គ១កញ្ចប់ និង ទឹក ៥០លីត្រ*

*រូបមន្ត ៣: ស្លឹកនិងផ្លែម៉ារិនដា៥គីឡូក្រាម ល្ហុងទុំ៥គីឡូក្រាម ម្នាស់ទុំ៥គីឡូក្រាម ស្កត្នោត៥គីឡូក្រាម និង ទឹក ១៥លីត្រ*

*រូបមន្ត ៤: សំណល់ត្រី១២គីឡូក្រាម ស្ករអំពៅ៧គីឡូក្រាម មីក្រូសរីរាង្គ១កញ្ចប់ និង ទឹក១៥លីត្រ*

## ២.៥ ថ្នាំពុលធម្មជាតិ

ការយល់ដឹងអំពីគុណវិបត្តិនៃសារធាតុគីមីកសិកម្ម បានជំរុញអោយកសិករស្វែងរកនូវវត្ថុធាតុដើមនានាសំរាប់ផលិតថ្នាំពុលដើម្បីទប់ទល់នឹងសត្វល្អិតបំផ្លាញ និងជំងឺរុក្ខជាតិនានាក្នុងកសិដ្ឋានរបស់ខ្លួន។

នៅតាមតំបន់នានាកសិករប្រើប្រភេទដើមឈើ ស្ដៅ រឺជីដើម្បីការពារដំណាំកសិកម្មពីពពួកសត្វបំផ្លាញ រឺជំងឺ។ ការអនុវត្តន៍ទាំងនេះត្រូវបានហៅថាជាចំណេះដឹងក្នុងស្រុក ហើយកំពុងត្រូវបានសិក្សាដោយអ្នកវិទ្យាសាស្ត្រដើម្បីអភិវឌ្ឍនូវថ្នាំពុលផ្សំពីរុក្ខជាតិទាំងនោះអោយកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

### ២.៥.១ វត្ថុធាតុដើមសំរាប់ធ្វើថ្នាំពុលធម្មជាតិ

មានប្រភេទរុក្ខជាតិ រឺតិណទេសជាច្រើនដែលមានផ្ទុកនូវសារធាតុមានប្រសិទ្ធភាពអាចការពារដំណាំពីការបំផ្លាញដោយពពួកសត្វបំផ្លាញ រឺជំងឺ។

- រុក្ខជាតិ រឺស្មៅដែលមានផ្ទុកនូវសារធាតុមានប្រសិទ្ធភាពសំរាប់ការពារដំណាំពីការបំផ្លាញដោយពពួកសត្វល្អិតចង្រៃ រឺជំងឺ មានដូចជា ស្ដៅ ( *អាហ្សាឌីរាច់តា អិនឌិកា*) ដើមទន្ទ្រាងខែត្រ ( *អឺប៉ាថរៀម អុដរាធុម*) ថ្នាំជក់ (*នីកូទ្វៃនា តាបាគុម*) ប្រេងខ្យល់ ម្លូ ( *ទីល្យូស្តុំរ៉ា គ្រីស្ប៉ា*) ផ្កាស្បៃរឿង ( *តាហ្គែត អឺរិចតា*) ស្លឹកគ្រៃ ( *ស៊ីមបូប៉ូហ្គុន ណាឌីស*) រមៀត ( *ឃឺឃ្យូម៉ា ឡុងហ្គា*) ម្ទេស រឺគល់ស្លឹកគ្រៃ។









**រូបភាព ២.១២ រុក្ខជាតិ រីតិណទេសសំរាប់ធ្វើថ្នាំពុលធម្មជាតិ**

## ២.៥.២ របៀបធ្វើថ្នាំពុលធម្មជាតិ

ដោយអាស្រ័យទៅតាមគោលបំណង និងទីតាំងនៃតំបន់ វត្ថុធាតុដើមដែលប្រើសំរាប់ធ្វើថ្នាំពុលធម្មជាតិ អាចត្រូវបានផ្លាស់ប្តូរ ។ ដំណើរការនៃការចម្រាញ់សារធាតុមានប្រសិទ្ធភាពពីវត្ថុធាតុដើមនានាអាចត្រូវបែងចែក

ជាពីររបៀបដូចខាងក្រោម ៖

១) វត្ថុធាតុដើមមួយចំនួនអាចយកមកប្រើបានភ្លាមៗ។ ចិញ្ច្រាំវាអោយល្អិតរួចបាច់ទៅជុំវិញគល់ដំណាំ។

២) សារធាតុប្រភេទខ្លះទៀតត្រូវការធ្វើអោយឡើងមេសិនទើបអាចប្រើបាន។ រយៈពេលនៃការឡើងមេគឺប្រហែល ៣០ ទៅ ៦០ ថ្ងៃ ដើម្បីចម្រាញ់សារធាតុមានប្រសិទ្ធភាពចេញពីវត្ថុធាតុដើមទាំងនេះ។ អាស្រ័យតាមសារធាតុ អាកុលអាចត្រូវបានបន្ថែមដើម្បីអោយការចម្រាញ់សារធាតុកាន់តែងាយស្រួល។



**រូបភាព ២.១៣ ការត្រៀមវត្ថុធាតុដើមសំរាប់ធ្វើថ្នាំពុលធម្មជាតិ**



**រូបភាព ២.១៤ ការដាក់អោយឡើងមេនៃវត្ថុធាតុដើមរយៈពេល ៣០ ទៅ ៦០ ថ្ងៃ**

***កំណត់សំគាល់:***

- ថ្នាំពុលធម្មជាតិមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងមនុស្ស
- ថ្នាំពុលធម្មជាតិដែលបានឡើងមេមានកំហាប់ខ្ពស់។ ត្រូវពង្រាវកំហាប់ពី ១០ ទៅ ១០០ ដង ជាមួយទឹកមុននឹងប្រើទៅលើដំណាំ ។

***ឧបសម្ព័ន្ធ:***

*រូបមន្តមួយចំនួនសំរាប់ធ្វើថ្នាំពុលធម្មជាតិមានបង្ហាញដូចខាងក្រោម:*

*រូបមន្តសំរាប់ការពារទ្រីប : ស្លឹកអាកាស្សា២គីឡូក្រាម ត្រួយស្តៅ១ធុង រំដេង២គីឡូក្រាម មីក្រូសរីរាង្គមានប្រសិទ្ធភាព១កែវ ស្ករដូង៣គីឡូក្រាម និង ទឹក៣០លីត្រ (រយះពេលឡើងមេ ២០ថ្ងៃ)*



*រូបមន្តសំរាប់ការពារដង្កូវកាត់ដើម : រមៀត១គីឡូក្រាម និងទឹក៤០លីត្រ (បុករមៀតអោយហ្មត់រួចដាក់ត្រាំក្នុងទឹកទុករយះពេលបីបួនថ្ងៃ)*



*រូបមន្តសំរាប់ការពារពពួកចៃ : ម្ទេសស្ងួត១គីឡូក្រាម និងទឹក១០លីត្រ (បុកម្ទេសអោយហ្មត់ហើយដាក់ត្រាំក្នុងទឹកទុករយះពេល ១យប់)*



*រូបមន្តការពារមមាចត្នោត : គ្រាប់ស្តៅ ១គីឡូក្រាម និងទឹក ២០លីត្រ (បុកគ្រាប់ស្តៅអោយហ្មត់ រួចដាក់ត្រាំក្នុងទឹកទុករយះពេល ១យល់)*



## ២.៦ ទឹកខ្មេះឈើ និងធ្យូង

ទឹកខ្មេះឈើ គឺជាអង្គធាតុរាវដែលបានមកពីការដុតធ្យូងក្នុងដំណើរការដុតកំដៅក្រោមល័ក្ខខ័ណ្ឌគ្មានខ្យល់។ ក្នុងកំឡុងពេលដុតនេះ ផ្សែងត្រូវបានធ្វើអោយកកស្រក់ទៅជាទឹកពណ៌ត្នោតហៅថា ទឹកខ្មេះឈើ (រូបភាព ២.១៥)។

មានការប្រើប្រាស់ច្រើនចំពោះទឹកខ្មេះឈើដូចជា ប្រើជាសារធាតុបំបាត់ក្លិន អង្គធាតុបន្សុទ្ធ រឺប្រើក្នុងវិស័យវេជ្ជសាស្ត្រជាដើម។ ចំពោះការប្រើប្រាស់ក្នុងវិស័យកសិកម្ម កសិករអាចប្រើទឹកខ្មេះឈើសំរាប់ការពារសត្វល្អិតបំផ្លាញនានា បង្កើនការលូតលាស់របស់ដំណាំ ឬធ្វើអោយដំណាំលូតលាស់បានល្អ។




ប្រភព: www.plai.co.th/organic/pic/icon/agr_1.jpg

**រូបភាព ២.១៥ សំណាកនៃទឹកខ្មេះឈើ**

### ២.៦.១ វត្ថុធាតុដើមសំរាប់ធ្វើទឹកខ្មេះឈើ និងធ្យូង

- ប្រភេទឈើណាមួយក៏បាន
- សំបកធុងសាមងចំណុះ ២០០ លីត្រ សំរាប់ធ្វើចង្ក្រាន
- បំពង់ទីពកោង (អង្កត់ផ្ចិត ១០សង់ទីម៉ែត្រ)
- បំពង់ទីពវែងប្រវែង ១ម៉ែត្រ (អង្កត់ផ្ចិត ១០សង់ទីម៉ែត្រ)
- ឥដ្ឋតាន់ចំនួន ៥
- ថ្មឥដ្ឋ



**រូបភាព ២.១៦ គំរូឡធ្វើទឹកខ្មេះឈើ**

## ២.៦.២ របៀបធ្វើទឹកខ្មេះឈើ និងធ្យូង

ឡមានសារៈសំខាន់ណាស់ក្នុងការធ្វើទឹកខ្មេះឈើ និងធ្យូង។

១) ដាក់សំបកធុងសាំងលើដុំឥដ្ឋហើយធ្វើជញ្ជាំង




២) ភ្ជាប់បំពង់ទីពទៅនឹងធុងសាំងដោយបិទនឹងដីឥដ្ឋ

៣) ដាក់ឈើ រឺឬស្សីចូលទៅក្នុងធុងសាំងដូចបង្ហាញក្នុងរូបភាព A និង B




៤) រៀបឥដ្ឋតាន់បង្កើតកន្លែងបង្កាត់ភ្លើងនៅពីមុខធុង



៥) បង្កាត់ភ្លើង






៦) ដុតភ្លើងអោយឆេះរហូតផ្សែងប្រែពីពណ៌សទៅពណ៌ប្រផេះ បន្ទាប់មកបន្ថយភ្លើងដោយត្រួតពិនិត្យបរិមាណខ្យល់ចូលតាមរយៈការកែតម្រូវរន្ធខ្យល់។

៧) បន្ទាប់ពីបន្ថយភ្លើងរយៈពេល ៣០នាទី ទៅ ១ម៉ោង ផ្សែងនឹងប្រែជាពណ៌សលាយលឿងស្រាល។ ពេលនេះចាប់ផ្ដើមត្រងយកទឹកខ្មេះឈើ។






៨) បន្ទាប់ពីប្រមូលយកទឹកខ្មេះឈើហើយ ផ្សែងនឹងប្រែទៅជាពណ៌សលាយខៀវ។ បន្ទាប់ពីនោះត្រូវបើករន្ធខ្យល់រយៈពេល ២០-៣០ នាទី។ ផ្សែងនឹងប្រែទៅជាពណ៌ខៀវច្បាស់ ដូចនេះត្រូវបិតរន្ធខ្យល់និងបំពង់ផ្សែង។ បន្ទាប់ពីបានរយៈពេល ១២-១៥ ម៉ោង ត្រូវបើកចេញដើម្បីប្រមូលយកធ្យូង។

***កំណត់សំគាល់:***

- ដើម្បីទទួលបានទឹកខ្មេះឈើដែលមានគុណភាពខ្ពស់ សីតុណ្ហភាពពេលដុតត្រូវនៅចន្លោះពី ៣០០ ទៅ ៤២៥ អង្សាសេ

- ក្នុងទឹកខ្មេះឈើមានទឹកប្រមាណ ៨០-៩០ភាគរយ និងសារធាតុសរីរាង្គ ២០០ ប្រភេទ

- ប៉េហាស (pH) នៃទឹកខ្មេះឈើគុណភាពល្អមានតំលៃប្រហែល ២,០-៣,២ និងដង់ស៊ីតេប្រហែល ១,០០៧-១,០២៤។

- បន្ទាប់ពីប្រមូលទឹកខ្មេះឈើពីដំណើរការដុតធ្យូងហើយ រក្សាទុករយៈពេល ៣ខែ។ ទឹកខ្មេះឈើនឹងចេញជាទំរង់ ៣ស្រទាប់ៈ ស្រទាប់ទី១គឺប្រេងស្រាល ស្រទាប់ទី២គឺទឹកខ្មេះឈើ និងស្រទាប់ទី៣គឺជាជ័រ។ មានតែស្រទាប់ទី២ទេដែលអាចយកមកប្រើជាទឹកខ្មេះឈើបាន។



**រូបភាព ២.១៧ ធ្យូងនិងទឹកខ្មេះឈើដែលផលិតជាមួយនឹងឡធ្វើដោយដៃ នៅប្រទេសថៃ**

## ២.៧ ការរៀបចំដីបែបអភិរក្ស

តួនាទីសំខាន់នៃការរៀបចំដីគឺការបង្កើនដល់ការលូតលាស់នៃដំណាំ ការជួយសំរួលដល់ការត្រួតពិនិត្យសំណាប និងការកំចាត់ស្មៅចង្រៃ (រូបភាព ២.១៨) ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំដីអាចផ្តល់ផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងផលិតភាពដីផងដែរ ប្រសិនបើការរៀបចំដីប្រព្រឹទ្ធទៅច្រើនហួសក៏រិត (រូបភាព ២.១៩) ។ នៅក្នុងទស្សវត្សថ្មីៗនេះ ការរៀបចំដីបែបអភិរក្សត្រូវបានអនុវត្តន៏យ៉ាងទូលំទូលាយព្រោះវាជួយបង្កើនការទប់ទឹក និងកាត់បន្ថយការបាត់បង់ដី ។





**រូបភាព ២.១៨ ប្រព័ន្ធភ្ជួររាស់ដីផ្សេងៗ**



**រូបភាព ២.១៩ សំណឹកដីដែលកើតឡើងលើដីកសិដ្ឋានដែលភ្ជួររាស់ហើយ**

### ២.៧.១ សំភារៈសំរាប់ការធ្វើដីបែបអភិរក្ស

- ស្មៅ ឬ សំណល់រុក្ខជាតិផ្សេងៗ
- ឧបករណ៍សំរាប់ធ្វើដីបែបអភិរក្សដូចជា ឈើបុស រ៉ី ចបជីក

### ២.៧.២ របៀបរៀបចំដីបែបអភិរក្ស

១) ទុកយ៉ាងតិច ៣០% នៃផ្ទៃដីអោយគ្របដោយស្មៅ ឬសំណល់រុក្ខជាតិ



២) កាត់បន្ថយការរៀបចំដីច្រើនសារ



ការរៀបចំដីធម្មតា



ការរៀបចំដីបែបអភិរក្ស

៣) ការរៀបចំដីដោយប្រើឈើបុស្សក៏មានប្រសិទ្ធភាពផងដែរ



ការប្រើឈើបុស្សសំរាប់ធ្វើដី

***កំណត់សំគាល់:***

- ឧបករណ៍រៀបចំដី ឬឧបករណ៍ថែទាំដំណាំ មានការប្រែប្រួលទៅតាមទំនៀមទំលាប់នៃការអនុវត្តន៍របស់កសិករក្នុងតំបន់
- ស្មៅ រឺសំណល់រុក្ខជាតិដែលសល់នៅលើផ្ទៃដីអាចជួយកាត់បន្ថយសំណើកដី ។

## ២.៨ ការទប់ស្កាត់ការហូរច្រោះ

ស្រែចំការនៅតំបន់ខ្ពង់រាប ងាយទទួលរងនូវសំណឹកដីយ៉ាងខ្លាំងជាពិសេសនៅក្នុងប្រទេសតំបន់ត្រូពិក ដែលតែងតែមានភ្លៀងខ្លាំងជាញឹកញាប់។ ការបាត់បង់ដី និងសារធាតុចិញ្ចឹមរបស់ដីដែលកើតឡើងដោយការហូរច្រោះពីដីកសិកម្មមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គុណភាពទឹកនៃប្រភពទឹកនានា និងបរិស្ថាន។ ការធ្វើរបាំងការពារការហូរច្រោះ គឺជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការបាត់បង់ដី និងសារធាតុចិញ្ចឹមរបស់ដីពីផ្ទៃដីកសិកម្ម។

### ២.៨.១ សម្ភារៈសំរាប់ធ្វើរបាំការពារការហូរច្រោះ

មានសំភារៈច្រើនប្រភេទសំរាប់បធ្វើរបាំងការពារការហូរច្រោះ

- ស្មៅ ឬ រុក្ខជាតិ (សំរាប់របាំងស្មៅការពារការហូរច្រោះ)
- សំបកស្រកីដូង (សំរាប់របាំងស្រកីដូងការពារការហូរច្រោះ)
- រុក្ខជាតិដុះនៅតាមដងទន្លេ (សំរាប់របាំងរុក្ខជាតិការពារការហូរច្រោះតាមជ្រាំងទន្លេ)

### ២.៨.២ របៀបធ្វើរបាំងការពារការហូរច្រោះ

១) សង្កេត និងគូសវាសពីលក្ខណៈនៃការហូរច្រោះលើដីចំការ

២) ជ្រើសរើសទីតាំងសមស្របសំរាប់ដាក់របាំងការពារការហូរច្រោះនៅក្នុងដីចំការនោះ។ របាំងការពារការហូរច្រោះនេះគួរតែដាក់អោយកាត់ទទឹងនៃលំហូរលើផ្ទៃនោះ។



**រូបភាប ២.២០ របាំងការពារការហូរច្រោះនៅលើដីចំការ**




**រូបភាព ២.២១ របាំងស្រកីដូងការពារការហូរច្រោះនៅលើដីកសិដ្ឋាន**

៣) បន្ទាប់ពីជ្រើសរើសសម្ភារៈដែលអាចប្រើសំរាប់បង្កើតរបាំងការពារការហូរច្រោះបានហើយ យកសម្ភារៈទាំងនោះទៅដាក់ក្នុងចំការ ។





**ស្រកីដូមុនពេលដំអោយទូក**



**បន្ទាប់ពីដំអោយទូក**

៤) ចំពោះការទប់ស្កាត់ការហូរច្រោះតាមមាត់ទន្លេ ត្រូវរក្សារុក្ខជាតិនានាដែលដុះតាមមាត់ទន្លេនោះ

***កំណត់សំគាល់:***

- វិធីទាំងនេះអាចជួយកាត់បន្ថយបានប្រហែល ៥០% ទៅ ៧០%នៃការបាត់បង់ដី និងសារធាតុចិញ្ចឹមរបស់ដី
- វិធីទប់ស្កាត់ការហូរច្រោះទាំងនេះអាចជួយបង្កើនការស្រូបយកទឹករបស់ដីផងដែរ
- គួរកប់ស្រកីដូងចូលទៅក្នុងដីយ៉ាងតិចប្រវែងពាក់កណ្តាលនៃស្រកីដូង

## ២.៩ កសិ-រុក្ខកម្ម

កសិ-រុក្ខកម្ម គឺជាប្រព័ន្ធកសិកម្មសមស្របមួយដែលមានអត្ថប្រយោជន៍ទាំងដោយផ្ទាល់និងប្រយោល មានដូចជា បន្ថយការសឹករីករិលនៃដី ជំរុញចលនាវដ្តធនធានធម្មជាតិ បង្កើនប្រាក់ចំណូលដល់កសិករ និងកាត់បន្ថយការបំពុលបរិស្ថាន។

### ២.៩.១ សំភារៈសំរាប់បង្កើតកសិ-រុក្ខកម្ម

- ប្រភេទដំណាំណាមួយ ដើមឈើ រឺ ស្មៅ ។

### ២.៩.២ របៀបបង្កើតកសិ-រុក្ខកម្ម

១) *កសិ-រុក្ខកម្មក្នុងផ្ទៃដីរាបស្មើនៃជំរាលភ្នំ:* សំណឹកដីធ្ងន់ធ្ងរ និងការបាត់បង់សារធាតុចិញ្ចឹមរបស់ដីតែងតែកើតឡើងជាញឹកញាប់នៅលើផ្ទៃដីរាបស្មើនៃជំរាលភ្នំ។ ដីទំនេរជាពិសេសនៅទីជំរាលអាចត្រូវគ្របដោយរុក្ខជាតិជាមួយនឹងកសិ-រុក្ខកម្ម។




**កសិ-រុក្ខកម្មជាមួយនឹងរបាំងការហូរច្រោះដោយប្រើស្មៅ**




**កសិ-រុក្ខកម្មជាមួយនឹងស្មៅ**




**កសិ-រុក្ខកម្មជាមួយដំណាំសេដ្ឋកិច្ច**




**កសិ-រុក្ខកម្មជាមួយតិណទេស និងដំណាំសេដ្ឋកិច្ច**



**រូបភាព ២.២២ ផ្ទៃរាបស្មើនៃទីជំរាលការពារការហូរច្រោះដោយប្រើស្មៅ**

២) *កសិ-រុក្ខកម្មនៅលើដីកសិកម្មតំបន់ខ្ពង់រាបៈ* កសិ-រុក្ខកម្មក៏មានអត្ថប្រយោជន៍ផងដែរសំរាប់ដីស្រែចំការ នៅតំបន់ខ្ពង់រាបទាំងទីជំរាល រឺទីរាបស្មើ ។




**ការដាំដើមឈើលាយចំរុះជាមួយដំណាំសេដ្ឋកិច្ច**




**ការដាំដើមឈើព័ទ្ធជុំវិញដីដាំដំណាំ**



**រូបភាព ២.២៣ ការដាំដើមឈើលាយចំរុះជាមួយដំណាំ**

៣) *កសិ-រុក្ខកម្មក្នុងបរិវេណដីភូមិ:* នៅជុំវិញដីភូមិ ដើមឈើដែលដាំឆ្លោះគ្នាជាមួយនឹងឈើហូបផ្លែ តិណទេស រឺដំណាំ ផ្តល់នូវសារធាតុសរីរាង្គជាច្រើន។




***កំណត់សំគាល់:***

- ដើមឈើដែលមានលក្ខណៈរំខាន់ដល់ការលូតលាស់នៃរុក្ខជាតិផ្សេងមិនអាចយកមកប្រើសំរាប់ធ្វើកសិ-រុក្ខកម្ម បានឡើយ
- កសិ-រុក្ខកម្មជួយជំរុញដល់វដ្តនៃធនធានធម្មជាតិ។

## ២.១០ ការសាងសង់ស្រះទឹក

ការសាងសង់ស្រះជាធម្មតាត្រូវបានធ្វើនៅកន្លែងមច្រោះ រឺនៅចំណុចដែលទឹកហូរចេញពីដីចំការ ។ ការសង់ស្រះអាចត្រូវធ្វើដោយជីកដី រឺបង្កើតជាទំនប់ដីកាត់ទទឹងចង្អូរនៃការហូរច្រោះនោះ។ មាត់ច្រកនៃស្រះច្រើនត្រូវបានសង់ដោយប្រើដុំថ្មធំៗ រឺចាក់បេតុង។ វាអាចទប់ភាគល្អិតនៃដីបានយ៉ាងល្អ ប៉ុន្តែមិនអាចទប់សារធាតុចិញ្ចឹមដែលរលាយក្នុងទឹកបានឡើយ ។ រុក្ខជាតិនានាក្នុងទឹកអាចស្រូបយកសារធាតុចិញ្ចឹមទាំងនេះ ។

### ២.១០.១ សម្ភារៈសំរាប់សាងសង់ស្រះ

- ឧបករណ៍សំរាប់ជីកដី
- ថ្ម រឺ បេតុង
- រុក្ខជាតិមួយចំនួនដូចជា ប្រភេទកក់ កំផ្លោក និង ពពួកចកផ្សេងៗ

### ២.១០.២ របៀបក្នុងការសាងសង់ស្រះ

១) សង្កេត និងគូសវាសពីលក្ខណៈលំហូរនៃការហូរច្រោះលើដីកសិដ្ឋាន



**រូបភាព ២.២៤ សំណឹកហូរច្រោះលើដីកសិដ្ឋាន**

២) ជ្រើសរើសកន្លែងដែលស្រះគួត្រូវសាងសង់ នៅក្នុង ឬជុំវិញដីចំការ

៣) ជីកដីនៅកន្លែងទឹកហូរចេញ ឬសង់ទំនប់ដីកាត់ទទឹងចង្អូរនៃការហូរច្រោះនោះ



**រូបភាព ២.២៥ ស្រះទឹកកំពុងសាងសង់**

៤) ប្រើវារីជាតិដើម្បីស្រូបយកសារធាតុចិញ្ចឹមដែលរលាយក្នុងទឹក



**រូបភាព ២.២៦ វារីជាតិដូចជា ពពួកកក់(រូបខាងឆ្វេង)**
**កំផ្លោក(រូបកណ្ដាល) និងចក(រូបខាងស្ដាំ)**

***កំណត់សំគាល់:***

- ភក់ដែលកើននៅក្នុងបាតស្រះគួរតែស្ដារចេញ

- ត្រូវប្រមូលយកវារីជាតិបន្ទាប់ពីវាលូតលាស់ធំធាត់ ។ រុក្ខជាតិទាំងនោះយកទៅធ្វើជាជីកំប៉ុស្ដិ៍បានយ៉ាងល្អ ។

## III. សេចក្តីសន្និដ្ឋាន

ការយល់ដឹងពីបញ្ហាបរិស្ថាន និងការបារម្ភកាន់តែខ្លាំងអំពីសុវត្ថិភាពអាហារ បានជំរុញអោយកសិករធ្វើការផ្លាស់ប្តូរការអនុវត្តន៍កសិកម្មរបស់ខ្លួនទៅរកលក្ខណៈកាន់តែស្និតស្នាលជាមួយបរិស្ថាន និងប្រកបដោយនិរន្តរភាព។ ចំពោះអ្នកប្រើប្រាស់ក៏ព្យាយាមរកនូវផលិតផលអាហារណាដែលមានសុវត្ថិភាពផងដែរ។ មានការអនុវត្តន៍កសិកម្មជាច្រើនដែលអាចនាំទៅរកកសិកម្មប្រកបដោយនិរន្តរភាព ប៉ុន្តែរាល់ការអនុវត្តន៍នីមួយៗត្រូវធ្វើអោយមានតុល្យភាពរវាងប្រព័ន្ធបរិស្ថាន សេដ្ឋកិច្ច និងសង្គម។

ការអនុវត្តន៍កសិកម្មសមស្របអាចជៀសផុត ឬកាត់បន្ថយការប្រើប្រាស់សារធាតុគីមីកសិកម្មនៅលើដីកសិកម្ម។ ផលិតផលសរីរាង្គដូចជា ជីកំប៉ុស្តិ៍ ជីទឹក រឺថ្នាំពុលធម្មជាតិអាចត្រូវបានប្រើទៅលើដីកសិកម្មជំនួសអោយសារធាតុសំយោគនានា។ មិនត្រឹមតែការអនុវត្តន៍ទូទៅដូចជាការធ្វើជីកំប៉ុស្តិ៍នោះទេ ចំណេះដឹងជឿនលឿនថ្មីៗអំពីការប្រើប្រាស់មីក្រូសរីរាង្គសំរាប់ការគ្រប់គ្រងសត្វល្អិត ឬការគ្រប់គ្រងជំងឺដំណាំក៏ត្រូវបានគេយកមកប្រើប្រាស់យ៉ាងទូលំទូលាយផងដែរ។

ការយល់ដឹងអំពីសារៈប្រយោជន៍នៃកសិកម្មសមស្រប គឺជាការចាំបាច់មិនត្រឹមតែចំពោះកសិករប៉ុណ្ណោះទេថែមទាំងចំពោះអ្នកប្រើប្រាស់ផលិតផលផងដែរ ។ ការអប់រំសិស្សានុសិស្សនៅតាមសាលាបឋមសិក្សាអំពីកសិកម្មសមស្របជួយអោយពួកគេយល់ដឹងអំពីការអនុវត្តន៍កសិកម្មដែលមានលក្ខណៈស្និទ្ធស្នាលជាមួយបរិស្ថាន និងការប្រើប្រាស់អាហារដែលមានសុវត្ថិភាព។

សៀវភៅណែនាំនេះ បានបង្កើតឡើងក្នុងកម្មវិធីសហប្រតិបត្តិការអន្តរជាតិក្រោមការសហការគ្នារវាងអង្គការក្រៅរដ្ឋាភិបាល និងសាកលវិទ្យាល័យ។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅនេះនឹងផ្តល់ការលើកទឹកចិត្តដល់អ្នកសម្របសម្រួលរបស់អង្គការក្រៅរដ្ឋាភិបាល ឬសាកលវិទ្យាល័យនានាក្នុងការពុះពារអភិវឌ្ឍន៍កសិកម្មប្រកបដោយនិរន្តរភាពតាមរយៈការលើកកំពស់ការអនុវត្តន៍កសិកម្មសមស្រប ។

## ឯកសារយោង


1) Abbott, J. C. and Markeham, J. P. 1990: Agricultural Economics and Marketing in the Tropics, 2nd edition, Longman, Essex, UK

2) Chihashi, S. and Xun, J. 2001: Studies on Phalaenopsis Growth and the Nutrient Absorption in Different Potting Materials, Department of Life Science, Aichi University of Education

3) Gerber, M. J. 1990: Principles of Agricultural Sustainability, http://newfarm.rodaleinstitute.org/features/1002/roland_lound/indext.shtml

4) Hasegawa, T. 1990: Biseibutunobunnruitodoutei (in Japanese), http://en.wikipedia.org/wiki/Coconut

5) Information of charcoal making, http://www.planenergy.co.th/node/38

6) Information of making compost, http://www.chikusan-kankyo.jp/taihiss /taihi/taihi.htm

7) Information of manure production, http://www.chikusan-kankyo.jp/ taihiss /taihi/taihi.htm

8) Information of wood vinegar, http://plai.co.th/organic/pic/icon/agr_1. jpg

9) Jin, C. X. and Römkens, M. J. M. 2001: Experimental Studies of Factors in Determining Sediment Trapping in Vegetative Filter Strips, Transactions of ASAE, 44(2), pp.277-288

10) Kadota, M. et al. 2004: Effects of Charcoal with Pyrolineous Acid and Farmyard Manure on Bedding Plientia, Horticulture, 101, pp.327 -332

11) Mihara, M. and Fujimoto, A. 2007: Sustainable Agriculture with Organic Fertilizer, Institute of Environment Rehabilitation and Conservation, Tokyo, Japan

12) Mihara, M. 2001: Nitrogen and Phosphorus Losses due to Soil Erosion during a Typhoon, Japan, Journal of Agricultural Engineering Research, 78(2), pp.209-216

13) Panyakul, W. and Sukjirattikan, J. 2003: Situation of Thai Organic Agriculture, World Organic Agriculture (in Thai), Earth Net Foundation, Bangkok, Thailand, p. 66

14) Pollution Control Department 2007: Chemical Pesticide, http://www.pcd.go.th/info_serv/haz_chemicals_use.html

15) Siriwattananon, L. and Mihara, M. 2008: Efficiency of Granular Compost in Reducing Soil and Nutrient Losses under Various Rainfall Intensities, Journal of Environmental Information Science, 36-5, pp.37-44

16) Takahashi, K., Hayashi, S., Nakamura, F., Tsuji, T., Tsuchiya, S. and Imaizumi, H. 2003: A Review on Buffer Width Required for Ecological Functions of Riparian Forests, Ecology and Civil Engineering, 5-2, pp.139-167

17) Treatment of Livestock Excrements. http://www.maff.go.jp/j/chikusan/ankyo/taisakn/t_siryo/05_bosui/pdf/3_pamphlet22.pdf

18) Xinxi, Jiang. 2004. Wood Charcoal and Pyroligneous Liquor Technology, http//www.cn/dz/en/charcoal-tech.htm